សេចក្តីថ្លែងការណ៍ឆ្លើយតបរបស់ដៃគូអភិវឌ្ឍន៍

# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ថ្លែងដោយ លោក ហ្សង់ ហ្វ្រង់ស្វា កូតាំង ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា

ក្នុងកិច្ចប្រជុំលើកទី ១៩ នៃគណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

ភ្នំពេញ ថ្ងៃ ទី ២៦ ខែ កញ្ញា ឆ្នាំ ២០១២

*ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*ឯកឧត្តម លោកជំទាវ លោក លោកស្រី*

**វិបស្សនាប្រចាំឆ្នាំលើកទី៦ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃ ទី ១៨-១៩ ខែ សីហា ឆ្នាំ ២០១២ បានបញ្ជាក់ថា យុទ្ធសាស្ត្រកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតែមានសុពលភាព ហើយការអនុវត្តកំពុងស្ថិតនៅលើផ្លូវត្រឹមត្រូវ។** ចាប់តាំងពីឆ្នាំ ២០០៤ មក មានកិច្ចប្រឹងប្រែង និងសមិទ្ធផលយ៉ាងច្រើនក្នុងការធ្វើឱ្យប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ រាជរដ្ឋាភិបាលកម្ពុជាមានលក្ខណៈទំនើប ក្រោមការប្តេជ្ញាមោះមុត និងក្រោមការគ្រប់គ្រង និងដឹកនាំ ប្រកបដោយបទពិសោធន៍ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ពួកយើងត្រូវបានរំលឹកឱ្យដឹងថា វិបស្សនាដែលនាយករដ្ឋមន្ត្រីចាត់ទុក កំណែទម្រង់ថាជា "បញ្ហាស្លាប់រស់ "។ ដៃគូអភិវឌ្ឍន៍យល់ស្រប ព្រោះថាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបញ្ជូនធនធានទៅកាន់កន្លែងខ្វះខាត ដែលត្រូវការសង្គ្រោះអាយុជីវិត អប់រំមនុស្សជំនាន់ក្រោយ លើកកំពស់លទ្ធភាពដើម្បីអភិវឌ្ឍធនធានមនុស្ស និងសម្រេចបាននូវ កំណើនដែលផ្តល់ផលដល់ពលរដ្ឋក្រីក្រ និងកំណើនដែលមានចីរភាព។ ហេតុនេះ ដៃគូអភិវឌ្ឍន៍សូមទាញអារម្មណ៍ រាជរដ្ឋាភិបាលកម្ពុជា លើបញ្ហាសំខាន់ៗមួយចំនួន។

**១. ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល។** ខណៈពេលដែលចំណូលមានការកើនឡើង ចំណូលនៅតែមិនគ្រប់តាមការកើនឡើងនូវតម្រូវការចំណាយសម្រាប់វិនិយោគលើការអភិវឌ្ឍ។ ចាំបាច់ត្រូវចាត់វិធានការបន្ទាន់ ដើម្បីសម្រេចបាននូវផែនការចំណូលសរុប ដែលអនុវត្តរួមគ្នាដោយនាយកដ្ឋានប្រមូលចំណូលនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ តាមការកំណត់នៃគោលនយោបាយកៀរគរចំណូល។ ការដាក់ឱ្យដំណើរការនូវប្រព័ន្ធប្រមូលចំណូលមិនមែនពន្ធដោយប្រើវិក្កយបត្រ (បណ្ណចំណូល) ដែលមានលក្ខណៈស្តង់ដារ និងការប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជាកាលពីពេលថ្មីៗកន្លងទៅ អំពីចេតនាក្នុងការពង្រីក ការប្រមូលពន្ធតាមរយៈប្រព័ន្ធ ធនាគារ គឺជាជំហានក្នុងទិសដៅត្រឹមត្រូវ ដែលចាំបាច់ត្រូវអនុវត្ត និងពង្រីកបន្ថែមទៀត។

**២. បង្កើនប្រសិទ្ធភាពនៃចំណាយលទ្ធកម្មសាធារណៈ។** ការកែលំអចំណាយលើទំនិញ និងសេវា តាមរយៈកិច្ចលទ្ធកម្មដែលកាន់តែមានលក្ខណៈប្រកួតប្រជែង និងកាន់តែមានតម្លាភាព ព្រមទាំងការប្រៀបធៀបថ្លៃអន្តរជាតិ តាមរយៈការអនុវត្តច្បាប់លទ្ធកម្មសាធារណៈ ដែលអាចសន្សំទឹកប្រាក់បានច្រើនក្នុងមួយឆ្នាំៗ។ ការចូលរួមកាន់តែខ្លាំងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យលទ្ធកម្មធំៗ ហើយការបង្កើនការចូលរួមរបស់អាជ្ញាធរជាតិសវនកម្មលើសុចរិតភាពនៃដំណើរការលទ្ធកម្ម គឺជាការចាំបាច់។ ការលើកកំពស់លទ្ធកម្មសាធារណៈ និងប្រព័ន្ធអភិបាលកិច្ចលើមូលដ្ឋានច្បាប់ នៅតែជាបញ្ហាប្រឈមចំបងនៃការអភិវឌ្ឍ

របស់កម្ពុជា ក្នុងការបង្កើនការផ្តល់សេវាសាធារណៈទៅកាន់ពលរដ្ឋក្រីក្របំផុត ពិសេសតាមរយៈវិស័យសុខាភិបាល និងអប់រំ ដោយផ្តល់ឱកាសកាន់តែច្រើន ក្នុងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជាប្រកបដោយសមធម៌។

**៣. ការធានាឱ្យថវិកាមានតម្លាភាព និងការបង្កើនភាពជឿទុកចិត្តនៃថវិកា។** បន្ថែមលើការបង្កើនចំណូលពន្ធ ការរៀបចំ និងការរាយការណ៍អំពីថវិការដ្ឋជារួម ក៏ចាំបាច់ត្រូវកែលំអផងដែរ ពោលគឺតាមរយៈ (១) ការព្យាករណ៍ និងការដាក់បញ្ចូលនូវការគាំទ្រគ្រប់ប្រភេទពីបរទេសក្នុងថវិកា (ការចាត់ថ្នាក់ចំណាយដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ សំខាន់ត្រូវប្រើប្លង់គណនីរបស់រដ្ឋាភិបាល) (២) វិភាជន៍ថវិកា នូវចំណាយមូលធនតាមវិស័យទាំងអស់របស់រដ្ឋាភិបាល (៣)វិភាជន៍ចំណាយថវិការួមមានចំណាយដែលផ្តល់ដោយម្ចាស់ជំនួយ ចំពោះកញ្ចប់អាទិភាពនានានៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (៤)ឯកសារដែលនាំទៅដល់ការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំត្រូវចែករំលែក និងផ្សព្វផ្សាយឱ្យបានទូលំទូលាយបំផុត ដើម្បីបង្កើនតម្លាភាព និងបង្កលក្ខណៈឱ្យមានការតម្រឹមវិភាជន៍ថវិការបស់ដៃគូអភិវឌ្ឍន៍កាន់តែបានល្អប្រសើរទៅកាន់វិស័យអាទិភាពនានា និង (៥) ចាំបាច់ត្រូវបង្កើនសមត្ថភាព និងលទ្ធភាពរបស់សភា និងអាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុពីខាងក្រៅ ក្នុងការត្រួតពិនិត្យផ្នែកផ្សេងៗនៃថវិកា ។

**៤. សង្គតិភាពរវាងអាទិភាពនានារបស់ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុ។** នេះជាចំណុចអាទិភាពសម្រាប់ រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ដើម្បីធានាឱ្យធនធានទាំងអស់សម្រាប់អភិវឌ្ឍត្រូវបានបែងចែកដោយប្រសិទ្ធភាព និងវិភាជន៍តាមបែបមួយដែលអាចជឿទុកចិត្តបាន។ ចំពោះវិភាជន៍ និងការរៀបចំកម្មវិធីរបស់ខ្លួន ដៃគូអភិវឌ្ឍន៍ និងរដ្ឋាភិបាល ត្រូវការឱ្យមានលទ្ធភាពព្យាករណ៍ និងសង្គតិភាពឱ្យបានច្រើនបំផុតរវាង ផយអជ ក្របខណ្ឌចំណាយរយៈពេលមធ្យម ផែនការ យុទ្ធសាស្ត្រថវិកា និងការប្រែក្លាយឱ្យទៅជាវិភាជន៍ និងការអនុវត្តថវិកាប្រចាំឆ្នាំរបស់ដៃគូអភិវឌ្ឍន៍ និងរបស់រាជរដ្ឋាភិបាល។ ករណីជាក់លាក់គឺថា ដៃគូអភិវឌ្ឍន៍តម្រូវឱ្យមានភាពច្បាស់លាស់មួយចំនួនអំពីសំណើសុំផ្តល់មូលនិធិថ្មី ដែលថាតើចាំបាច់ត្រូវប្រើ ទម្រង់ផែនការយុទ្ធសាស្ត្រថវិកា ឬទម្រង់នេះត្រូវប្រើសម្រាប់តែក្នុងដំណាក់កាលទី ៣ នៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់ពីឆ្នាំ ២០១៥ តទៅ។

**៥. ចំណងទាក់ទងរវាងកំណែទម្រង់នានារបស់ជាតិ។** វិបស្សនាប្រចាំឆ្នាំបានសន្និដ្ឋានថា កំណែទម្រង់សំខាន់ៗទាំងបី ពោលគឺ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងវិសហមជ្ឈការ និងវិមជ្ឈការ ចាំបាច់ត្រូវផ្សារភ្ជាប់គ្នាឱ្យបាន ជិតស្និទ្ធដើម្បីទទួលបានជោគជ័យ។ ឧទាហរណ៍ ការអនុវត្តប្រព័ន្ធព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុ និងកំណែទម្រង់អង្គភាពថវិកា ក្រោមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តម្រូវឱ្យមានការសម្របសម្រួលកាន់ តែខ្លាំង និងកិច្ចសហការកាន់តែជិតស្និទ្ធ ជាមួយស្ថាប័នទទួលបន្ទុកកំណែទម្រង់រដ្ឋបាលសាធារណៈ និងស្ថាប័នទទួលបន្ទុកការងារកំណែទម្រង់វិមជ្ឈការ និងវិសហ-មជ្ឈការ។ ចំណុចនេះគប្បីដាក់បញ្ចូលនៅក្នុងផែនការសកម្មភាពរួម និងតាមលំដាប់លំដោយចំពោះកំណែទម្រង់ទាំងបី។ ទោះបីជា មានកិច្ចប្រឹងប្រែងជាក់ច្បាស់ក្នុងការផ្សារភ្ជាប់កំណែទម្រង់ទាំងបីដោយកំណត់សូចនាករតាមដានរួមដាច់ដោយឡែកពីគ្នាក្តី មានកិច្ចការជាច្រើនបន្ថែមទៀត ដើម្បីជំរុញអោយចូលរួមពីក្រសួង និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា។

សូមអរគុណ។